# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១០

(០១/០៣/២០១០-៣១/៣/២០១០)

## I / សភាពការណ៍គ្រឿងញៀនទូទៅ :

ក្នុងខែនេះ តាមរបាយការណ៍ដែលផ្តល់ដោយមន្ទីរប្រឆាំងគ្រឿងញៀន ពិនិត្យឃើញមាន មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តពោធិសាត់ និង ខេត្តបន្ទាយមានជ័យ ដែលបានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀន ។ តាមរយៈការបង្ក្រាបនេះ បានបង្ហាញថា មេតំហ្វេតាមីនទឹកកក(ICE)នៅតែបន្តមានសកម្មភាពជួញដូរចែកចាយ ច្រើនជាងប្រភេទគ្រឿងញៀនដទៃទៀត ។ ក្រៅពីនោះ ក៏មាន២ករណី កូកាអ៊ីន ដែលធ្វើសកម្មភាពដោយក្រុមជួញដូរគ្រឿងញៀនមកពីអាហ្វ្រិកខាងលិច ។ យើងក៏បានកត់សំគាល់ឃើញផងដែរថា ពួកឈ្មួញគ្រឿងញៀនបានប្តូររូបភាពពីការនាំ ហេរ៉ូអ៊ីន ឆ្លងកាត់ច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ទៅជាការផ្ញើតាមកញ្ចប់បញ្ញើនានាវិញ ។

## II / លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

-ថ្ងៃទី១០ខែមីនាឆ្នាំ២០១០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានជួបពិភាក្សាការងារជាមួយលោកជំទាវ **ម៉ាការេត អាដាមសុន** ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ។ នៅក្នុងកិច្ចពិភាក្សាការងារ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានស្នើសុំភាគីអូស្ត្រាលី ទី១)ជួយសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ (ភាគីអូស្ត្រាលីបានយល់ព្រមបណ្តុះបណ្តាលជំនាញព័ត៌មានចារកម្ម), ទី២)ជួយផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមានការយល់ដឹងពីគ្រោះថ្នាក់នៃការផលិតប្រេងម្រះព្រៅភ្នំ និងការកែប្រែជីវភាពទៅប្រកបរបរដាំដំណាំស្របច្បាប់(ភាគីអូស្ត្រាលីបានគាំទ្រគំនិតនេះ), ទី៣) ស្នើសុំឱ្យជួយពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន និង ក្រុមការងារគ្រឿងញៀន/អេដស៍ (ភាគីអូស្ត្រាលីទទួលយកសំណើនេះ ហើយនឹងពិភាក្សាជាមួយក្រុមអ្នកជំនាញ), ទី៤)ចំពោះការជ្រើសរើស ឃុំ សង្កាត់ អាទិភាពប្រហែល២៥% (ពី៣៥០ ទៅ៤០០ឃុំ/សង្កាត់) ភាគីអូស្ត្រាលីនឹងគាំទ្រគំរោងការនេះ ។

ដោយឡែក ភាគីអូស្ត្រាលីក៏មានសំណើពីរផងដែរគឺ ទី១) ស្នើសុំអាជ្ញាធរជាតិអនុញ្ញាតឱ្យដៃគូមួយចំនួនទៀតអនុវត្តកម្មវិធីស៊ីរ៉ាំង/ម្ជុល សំរាប់អ្នកប្រើគ្រឿងញៀនដោយការចាក់ ។ បញ្ហានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើឱ្យភាគីអូស្ត្រាលីផ្តោតការយកចិត្តទុកដាក់គាំទ្រដល់ការធ្វើសកម្មភាពឆ្លើយតបជាពហុវិស័យវិញ ព្រោះការចែកចាយស៊ីរ៉ាំង/ម្ជុលគ្រាន់តែកាត់បន្ថយការឆ្លងមេរោគអេដស៍ប៉ុណ្ណោះ គឺមិនបានកាត់បន្ថយការប្រើប្រាស់គ្រឿងញៀនទេ, ទី២) សុំឱ្យគាំទ្រកល់កម្មវិធីព្យាបាលជំនួសដោយឱសថមេតាដូន សំរាប់អ្នកញៀនគ្រឿងញៀនហេរ៉ូអ៊ីន ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានគាំទ្រសំណើនេះ ដោយស្នើឱ្យដៃគូអនុវត្តគំរោងសហការជាមួយក្រសួងសុខាភិបាល ហើយអាជ្ញាធរជាតិនឹងតាមដានការអនុវត្តន៍គំរោងនេះ ។

-ថ្ងៃទី១៧ខែមីនាឆ្នាំ២០១០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានដឹកនាំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៩ និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ ក្នុងគោលបំណងរកឱ្យឃើញនូវចំណុចប្រឈម ក្នុងការងារកាត់បន្ថយតម្រូវការគ្រឿងញៀន ការផ្គត់ផ្គង់គ្រឿងញៀន ការបង្ក្រាប ព្យាបាល អប់រំ អ្នកញៀនគ្រឿងញៀន ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធ្វើការកែលំអ សំរាប់ការអនុវត្តន៍នៅក្នុងឆ្នាំ២០១០ ឱ្យទទួលបានប្រសិទ្ធភាព ។

-ថ្ងៃទី០១ខែមីនាឆ្នាំ២០១០ **ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតរុស្ស៊ី និងក្រុមប្រតិភូស្ថាប័នត្រួតពិនិត្យគ្រឿងញៀនរុស្ស៊ី ចូលជួបសំដែងការគួរសម និងពិភាក្សាការងារ ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមអនុប្រធាន អជបគញ បានស្នើសុំឱ្យភាគីរុស្ស៊ីបន្តជួយបណ្តុះបណ្តាលជំនាញដល់មន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា និងជួយផ្តល់ដល់កម្ពុជានូវអ្នកជំនាញការរយៈពេលវែងឬខ្លី ប្រចាំនៅអគ្គលេខាធិការដ្ឋាន អជបគញ, និងស្នើសុំឱ្យមានគំរោងទ្វេភាគី កម្ពុជា-រុស្ស៊ី រយៈពេលវែង ព្រមទាំងស្នើសុំមន្ទីរពិសោធន៍គ្រឿងញៀនសំរាប់ដាក់នៅតាមភូមិភាគ និងការផ្លាស់ប្តូរប្រតិភូទៅបំពេញទស្សនកិច្ចដកពិសោធន៍លើការងារត្រួតពិនិត្យគ្រឿងញៀន ។ ឯកអគ្គរដ្ឋទូតរុស៊ីបានសន្យាពាំនាំនូវសំណើរសុំខាងលើជូនរដ្ឋាភិបាលរុស្ស៊ីដើម្បីពិនិត្យ ។

## ***១-ការកាត់បន្ថយតម្រូវការគ្រឿងញៀន :***

-តបតាមសំណើរបស់ សមាគមយុវជនខ្មែរ ដែលជាដៃគូរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការងារអប់រំបង្ការការប្រើបំពានគ្រឿងញៀននៅក្នុងសាលា និង សហគមន៍ អគ្គលេខាធិការដ្ឋាន អជបគញ បានជួយធ្វើការសំរបសំរួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៤ ដើម្បីសមាគមនេះ បានចុះធ្វើសកម្មភាពអប់រំបង្ការ ក្នុងនោះរួមមាន :

រាជធានីភ្នំពេញ ធ្វើនៅ វិទ្យាល័យសម្តេចហ៊ុន សែនភ្នំពេញថ្មី វិទ្យាល័យហ៊ុន សែនជម្ពូវ័ន និង សង្កាត់ភ្នំពេញថ្មី

ខេត្តបាត់ដំបង ធ្វើនៅវិទ្យាល័យនេតយ៉ង់ វិទ្យាល័យសម្តេចឪ អនុវិទ្យាល័យអនុវត្តន៍ និង សង្កាត់រតនះ

ខេត្តបន្ទាយមានជ័យ ធ្វើនៅវិទ្យាល័យអូរអំបិល និង សង្កាត់អូរអំបិល

ខេត្តសៀមរាប ធ្វើនៅវិទ្យាល័យពួក និង ឃុំពួក

-អគ្គលេខាធិការដ្ឋាន អជបគញ តាមសំណើរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា អង្គការអាដ្រាកម្ពុជា និង អង្គការម៉េឌីខាំ បានចាត់មន្ត្រីទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការត្រួតពិនិត្យថ្នាំជក់ ពីថ្ងៃទី០៣-០៤ខែមីនា

ឆ្នាំ២០១០ នៅសណ្ឋាគារភ្នំពេញ ។

-អគ្គលេខាធិការដ្ឋានអជបគញបតាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព(**PDP**) បានចាត់មន្ត្រីទៅចូលរួមក្នុងកិច្ចប្រជុំស្តីពីគោលនយោបាយគ្រឿងស្រវឹងនៅកម្ពុជា ដើម្បីពិភាក្សាគ្នារវាងអង្គការ និងស្ថាប័នពាក់ព័ន្ធ និងតាមដានព័ត៌មានថ្មីៗពាក់ព័ន្ធនឹងគោលនយោបាយគ្រឿងស្រវឹង (២៥/៣/២០១០) ។

-អគ្គលេខាធិការដ្ឋាន អជបគញ សហការជាមួយអង្គការ **JICA** តាមរយៈគំរោងទ្វេភាគី កម្ពុជា-ជប៉ុន ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួន ២០ រូប នៅខេត្តកំពង់ចាម (១៩/៣/២០១០) ។

ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តកិច្ចសហការសំរបសំរួលនិងជំរុញបណ្តាខេត្ត-រាជធានី ឱ្យយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន សរុបបានចំនួន 38.173 នាក់ ក្នុងនោះរួមមាន ÷

| ឈ្មោះ រាជធានី-ខេត្ត | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|
| ខេត្តបាត់ដំបង | ផលប៉ះពាល់នៃគ្រឿងញៀន (លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជាពលរដ្ឋ) | 10.630 នាក់ |
| ខេត្តប៉ៃលិន | ផលប៉ះពាល់នៃគ្រឿងញៀន (ធ្វើសកម្មភាពក្នុងចំណោមបុគ្គលិកកាស៊ីណូ និង សេវាកំសាន្ត) | 538 នាក់ |
| ខេត្តកំពង់ចាម | ផលប៉ះពាល់នៃគ្រឿងញៀន(ធ្វើសកម្មភាពក្នុងចំណោមកម្លាំងប្រដាប់អាវុធ) | 50 នាក់ |
| ខេត្តកំពង់ធំ | ផលប៉ះពាល់នៃគ្រឿងញៀន(លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស នាយទាហាន នាយទាហានរង) | 1.719 នាក់ |
| ខេត្តកំពត | ផលប៉ះពាល់នៃគ្រឿងញៀន(លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស) | 33.735 នាក់ |
| ខេត្តកែប | ផលប៉ះពាល់នៃគ្រឿងញៀន(ប្រជាពលរដ្ឋ) | 152 នាក់ |
| ខេត្តកណ្តាល | ផលប៉ះពាល់នៃគ្រឿងញៀន(លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស) | 4.389 នាក់ |
| ខេត្តក្រចេះ | ផលប៉ះពាល់នៃគ្រឿងញៀន(ប្រជាពលរដ្ឋ) | 57 នាក់ |
| ខេត្តមណ្ឌលគិរី | ផលប៉ះពាល់នៃគ្រឿងញៀន(លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រជាពលរដ្ឋ) | 1.470 នាក់ |
| ខេត្តសៀមរាប | ផលប៉ះពាល់នៃគ្រឿងញៀន(នគរបាលប៉ុស្តិ៍រដ្ឋបាល គណៈបញ្ជាការឯកភាពស្រុក មេឃុំ) | 70 នាក់ |
| ខេត្តកំពង់ស្ពឺ | ច្បាប់គ្រឿងញៀន និង ផលប៉ះពាល់នៃគ្រឿងញៀន(មន្ត្រីអាជ្ញាធរក្រុង ប្រជាពលរដ្ឋ) | 256 នាក់ |
| ខេត្តព្រះសីហនុ | ផលប៉ះពាល់នៃគ្រឿងញៀន(លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស) | 1.370 នាក់ |
| ខេត្តឧត្តរមានជ័យ | ផលប៉ះពាល់នៃគ្រឿងញៀន(ក្រុមប្រឹក្សាឃុំ) | 51 នាក់ |
| បណ្តាញសមាគមយុវជនខ្មែរ | ផលប៉ះពាល់នៃគ្រឿងញៀន (ធ្វើសកម្មភាពនៅខេត្តប៉ៃលិន ក្នុងចំណោមស្ត្រីបំរើសេវាកំសាន្ត) | 351 នាក់ |
| **សរុប** | | 54.838 នាក់ |

## ២-ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :

ខែមីនានេះ អង្គភាពអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់បង្ក្រាបបទល្មើស ទទួលបានលទ្ធផលដូចខាងក្រោម :

- **បទល្មើស** បង្ក្រាបបាន **២៧ ករណី**
- **ឃាត់ខ្លួនជនល្មើស ៦១ នាក់** (ប្រុស ៥០ នាក់ ស្រី ១១ នាក់) បញ្ជូនទៅតុលាការ ក្នុងនោះមាន ÷ ជនជាតិខ្មែរ ៥៥ នាក់ (ប្រុស ៤៦ នាក់ ស្រី ៩ នាក់), វៀតណាម ៣ នាក់ (ប្រុស ១ នាក់ ស្រី ២ នាក់) ហ្គីណេប៊ីសាវ ១ នាក់(ប្រុស), នីហ្សេរីយ៉ា ២ នាក់(ប្រុស) ។
- **ចាប់យក** មេតំហ្វេតាមីន **WY** ២.៤៦៣ គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE** ៦១៨,១៩ ក្រាម, ហេរ៉ូអ៊ីន ១៩,៨០ ក្រាម, អ៊ិចស្តាស៊ី ១០ គ្រាប់, កូកាអ៊ីន ៩២០,៦៨ ក្រាម, កញ្ឆាក្រៀម ៧,៨០ ក្រាម, កាំភ្លើងខ្លី ២ ដើម, កាំភ្លើងវែង ១ ដើម, រថយន្ត ២ គ្រឿង, ម៉ូតូ ១ គ្រឿង ។

## អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើស រួមមាន ៖

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៦** | **១៤** | **២** | ៦ | ១៤ | ២ | | | | | | |
| ២ | រាជធានីភ្នំពេញ | **៩** | **៣០** | **៥** | ៦ | ៩ | ២ | ៣ | ២១ | ៣ | | | |
| ៣ | កំពង់ចាម | **៣** | **៣** | **០** | ៣ | ៣ | ០ | | | | | | |
| ៤ | ព្រះសីហនុ | **១** | **៣** | **១** | ១ | ៣ | ១ | | | | | | |
| ៥ | សៀមរាប | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៦ | ស្ទឹងត្រែង | **០** | **១** | **០** | | | | | | | ០ | ១ | ០ |
| ៧ | កណ្តាល | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៨ | បាត់ដំបង | **១** | **២** | **១** | ១ | ១ | ០ | | | | ០ | ១ | ១ |
| ៩ | ក្រចេះ | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ១០ | ប៉ៃលិន | **១** | **០** | **០** | ១ | ០ | ០ | | | | | | |
| ១១ | កំពង់ស្ពឺ | **១** | **៤** | **២** | ១ | ៤ | ២ | | | | | | |
| ១២ | ពោធិសាត់ | **២** | **១** | **០** | ២ | ០ | ០ | | | | ០ | ១ | ០ |
| **សរុប** | | **២៧** | **៦១** | **១០** | **២៤** | ៣៧ | ៧ | **៣** | ២១ | ៣ | **០** | ៣ | ១ |

អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការបូកសរុបទិន្នន័យសារធាតុគីមីផ្សំ ដែលមានអាជ្ញាប័ណ្ណនាំចូល ប្រចាំខែមីនា ឆ្នាំ២០១០ សរុបមានចំនួន **5.320.000 Kgs** ក្នុងនោះរួមមាន ៖

| ឈ្មោះ សារធាតុគីមី | អាជ្ញាប័ណ្ណ ក្រសួង សុខាភិបាល | | អាជ្ញាប័ណ្ណក្រសួង ឧស្សាហកម្ម | | អាជ្ញាប័ណ្ណ CDC | | សរុប | |
|---|---|---|---|---|---|---|---|---|
| | Kg | L | Kg | L | Kg | L | Kg | L |
| **Caustic Soda** | | | 400 | | 300.000 | | **300.400** | |
| **Oxalic Acid** | | | | | 200.000 | | **200.000** | |
| **Sodium Carbonate** | | | | | 300.000 | | **300.000** | |
| **Sodium Hypochloride** | | | | | 4.000.000 | | **4.000.000** | |
| **Sodium Sulfate** | | | | | 500.000 | | **500.000** | |
| **Toluene** | | | 6.000 | | | | **6.000** | |
| **Ethyl Acetate** | | | 1.600 | | | | **1.600** | |
| **Xylene** | | | 4.000 | | | | **4.000** | |
| **Solvents** | | | 8.000 | | | | **8.000** | |
| **Total :** | | | **20.000** | | **5.300.000** | | **5.320.000** | |

ដោយឡែក ដំណាំកញ្ឆា មានសមត្ថកិច្ចចំនួន ៤ ខេត្ត ដែលបានចុះទៅបំផ្លាញ សរុបមានចំនួន ១០០៦ ដើម ស្មើនឹង ប្រហែល ២០១ ម៉ែត្រក្រឡា ក្នុងនេះគឺ ខេត្តពោធិសាត់បំផ្លាញបាន ១៦២ ដើម, ខេត្តកំពង់ចាម ៥៦០ ដើម, ខេត្តប៉ៃលិន ២៦០ ដើម, ខេត្តក្រចេះ ២៤ ដើម និងឃាត់ខ្លួនជនល្មើស១នាក់ (ប្រុស) បញ្ជូនទៅសាលាដំបូងខេត្ត ។

**ការពង្រឹងយន្តការអនុវត្តគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ៖**

-ខេត្តពោធិសាត់ បានធ្វើការណែនាំការអនុវត្តន៍មូលដ្ឋានគ្រឹះទាំង៥ នៃផែនការប្រៀបសមរភូមិប្រឆាំងបទល្មើស គ្រឿងញៀន ដល់មន្ត្រីនគរបាល ចាប់ពីថ្នាក់ការិយាល័យប្រឆាំងគ្រឿងញៀន រហូតដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល សរុប៦៤នាក់ ។

-ខេត្តកំពង់ចាម បានធ្វើការណែនាំការអនុវត្តន៍មូលដ្ឋានគ្រឹះទាំង៥ នៃផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿង ញៀន ដល់មន្ត្រីនគរបាល ចាប់ពីថ្នាក់ការិយាល័យប្រឆាំងគ្រឿងញៀន រហូតដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល សរុប ២៩១ នាក់ ។

***៣.ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន :***

-ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ នៅអគ្គលេខាធិការដ្ឋាន អជបគញ មានបើកកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាង អនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលមានការអញ្ជើញចូលរួម ពីតំណាងក្រសួងសុខាភិបាល, តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា, តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រសួងយុត្តិធម៌ និង ក្រសួងពាក់ព័ន្ធមួយចំនួនទៀត ។

-អគ្គលេខាធិការដ្ឋាន អជបគញ តាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ បានចាត់មន្ត្រី ២ រូប ឱ្យចូលជាសមាជិកក្រុមការងារស្នូល សំរាប់រៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យ ឆ្លើយតបការរាលដាលមេរោគអេដស៍ ជម្ងឺអេដស៍ លើកទី៣ (ឆ្នាំ២០១១-២០១៥) ។

-អង្គការ **AusAID** បានធ្វើការត្រួតពិនិត្យលទ្ធផលប្រចាំ ឆមាស លើកដំបូងរបស់គំរោង **HAARP** ដោយបានបង្ហាញនូវអនុសាសន៍ចំនួន ៣ ដែលត្រូវធ្វើការកែលំអគឺ **ទី១** ត្រូវធ្វើការកែសំរួល រៀបចំកិច្ចសន្យាការងារជាមួយដៃគូ **ទី២** បង្កើនការគាំទ្រដល់លេខាធិការដ្ឋាន និងក្រុមការងារគ្រឿងញៀន/អេដស៍ **ទី៣** ត្រូវធានាឱ្យបាននូវតុល្យភាពនៃកម្មវិធីរវាងការផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ និងកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីគាំទ្រដល់បរិយាកាសមួយដែលសំរួលដល់ប្រសិទ្ធភាពនៃការផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ ។

***៤.ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ :***

-អគ្គលេខាធិការដ្ឋាន អជបគញ តាមរយៈគំរោង កម្ពុជា-ជប៉ុនបានទទួលនូវសំភារៈបរិក្ខារមួយចំនួន សំរាប់ដំណើរការការងារនៅក្នុងមន្ទីរពិសោធន៍ ។

-អគ្គលេខាធិការដ្ឋាន អជបគញ សហការជាមួយស្ថាប័នត្រួតពិនិត្យគ្រឿងញៀនសហព័ន្ធរុស្ស៊ី បើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ ពីជំនាញត្រួតពិនិត្យគ្រឿងញៀន សរុបបានចំនួន ៥២ នាក់ ដែលមានសមាសភាពមកពី កងនគរបាល កងរាជអាវុធហត្ថ អគ្គនាយកដ្ឋានគយ-រដ្ឋាករ អគ្គនាយកដ្ឋានកាំកុងត្រូល ។

-អគ្គលេខាធិការដ្ឋាន អជបគញ តាមសំណើរបស់គណៈកម្មការជាតិសន្តិសុខលំហសមុទ្រ បានចាត់មន្ត្រីចូលរួមប្រជុំនៅទីស្តីការក្រសួងការពារជាតិ នាថ្ងៃទី៣០ខែមីនាឆ្នាំ២០១០ ស្តីពីការរៀបចំអនុក្រឹត្យស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការសន្តិសុខលំហសមុទ្រ ។

***៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ :***

-អគ្គលេខាធិការ អជបគញ បានទៅចូលរួមប្រជុំ **IDEC** នៅទីក្រុងបាងកក ប្រទេសថៃ (០១-០៣/៣/២០១០) ។

-ថ្ងៃទី២៤ខែមីនាឆ្នាំ២០១០ នៅអគ្គលេខាធិការដ្ឋាន អជបគញ មានបើកកិច្ចប្រជុំគណៈកម្មការចំរុះ កម្ពុជា-ជប៉ុន ដើម្បីបូកសរុបលទ្ធផលបញ្ចប់គំរោងទ្វេភាគី កម្ពុជា-ជប៉ុន ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

-អគ្គលេខាធិការដ្ឋាន អជបគញ បានចាត់មន្ត្រី០១រូប ទៅចូលរួមប្រជុំមន្ត្រីទំនាក់ទំនងគំរោង **H15** (គំរោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូនៃបណ្តាប្រទេសហត្ថលេខី **MOU** ក្នុងមហាអនុតំបន់ទន្លេមេគង្គ ។ កិច្ចប្រជុំនេះ ធ្វើឡើងដើម្បីពិនិត្យលើការអនុវត្តន៍ផែនការសកម្មភាពគំរោង **H15** និងពិភាក្សាអំពីការត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់

ខ្ពស់ និង ថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសហត្ថលេខីនៃអនុស្សារណៈយោគយល់គ្នាឆ្នាំ១៩៩៣ ក្នុងការងារ : ទី១) ពិគ្រោះយោបល់ដើម្បីកំណត់អំពីគោលនយោបាយត្រួតពិនិត្យគ្រឿងញៀនក៏រិតតំបន់, ទី២) ជួយជំរុញរដ្ឋាភិបាលក្នុងការពិនិត្យឡើងវិញអំពីផែនការសកម្មភាពត្រួតពិនិត្យគ្រឿងញៀន និងការផ្តួចផ្តើមគំនិតថ្មីៗ, ទី៣) ពង្រឹងសមត្ថភាពត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងតំបន់, ទី៤) ជួយអនុវត្តផែនការសកម្មភាពតូចៗដើម្បីគាំទ្រដល់កម្មវិធីអនុតំបន់ ។ អង្គប្រជុំ បានពិនិត្យលើគំរោងសំខាន់ៗ ចំនួនពីរគឺ គំរោងស្តីពី ការពង្រឹងការត្រួតពិនិត្យការចរាចរសារធាតុគីមីផ្សំខុសច្បាប់ (ត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ២០១០) និង គំរោងស្តីពីភាពជាដៃគូក្នុងការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធនឹងគ្រឿងញៀន (PATROL) ។

## III/ ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១០ :

### *១-ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :*

-បន្តកិច្ចសហការនិងសំរបសំរួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ តាមអនុសាសន៍ណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី នាថ្ងៃទី១៧ខែមីនាឆ្នាំ២០១០ ក្នុងនោះតាមរយៈ ÷

▯ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ជំរុញឱ្យសិប្បកម្ម ក្រុមហ៊ុនឧស្សាហកម្មនានា សរសេរ "សារអប់រំពីគ្រឿងញៀន" ដាក់នៅលើផលិតផលរបស់ខ្លួន ។

▯ក្រសួងព័ត៌មាន ជំរុញឱ្យគ្រប់ស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋនិងឯកជន សារព័ត៌មាន សរសេរ "សារអប់រំពីគ្រឿងញៀន" សិល្បករ សិល្បការិនី ពិធីករ ពិធីការិនី បន្តនិងបង្កើនការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

▯ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជំរុញក្រុមហ៊ុនផលិតខ្សែភាពយន្ត ខារ៉ាអូខេ ចម្រៀងកាយវិការ ជាដើម ឱ្យសរសេរ "សារអប់រំគ្រឿងញៀន" ឬ ដាក់ "ស្ព័តអប់រំពីគ្រឿងញៀន" នៅគ្រប់ក្បាល **Casette** វីដេអូ មុននឹងចេញទិដ្ឋាការឱ្យចាក់ផ្សាយ ។

▯ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងទេសចរណ៍ ជំរុញឱ្យម្ចាស់រថយន្តទេសចរ ចូលរួមផ្សព្វផ្សាយតាមរយៈ ការបិទសារ ឬ ចាក់ស្ព័តអប់រំពីគ្រឿងញៀន ។ ដោយឡែក ក្រសួងទេសចរណ៍ត្រូវមានកិច្ចសន្យារដ្ឋបាលឱ្យបានច្បាស់លាស់ជាមួយម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ ក្លឹបកំសាន្តនានា ។

#### *២-ការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន*

-បន្តជំរុញការសាងសង់មជ្ឈមណ្ឌល ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនថ្នាក់ជាតិ ។

-បន្តជំរុញការរៀបចំអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការរៀបចំសេចក្តីព្រាងស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាលនិងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញខេត្ត-រាជធានី ឱ្យធ្វើបញ្ជីឈ្មោះ ឃុំ សង្កាត់អាទិភាព សំរាប់ធ្វើសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅឆ្នាំ ២០១០, ឈ្មោះនិងទីតាំងមណ្ឌលសុខភាព, ឈ្មោះទីតាំងនិងវិសាលភាពនៃការអនុវត្តន៍ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀន និងជម្ងឺអេដស៍នៅខេត្ត-រាជធានី ។

-បន្តតម្លើងផែនទីគោលដៅមណ្ឌលសុខភាពរបស់អង្គការ ខាន់ណា និងមណ្ឌលសុខភាពរបស់ ឃុំ សង្កាត់ អាទិភាព ។

-ត្រៀមពិធីចុះហត្ថលេខាលើគំរោងការអនុវត្តកម្មវិធី ព្យាបាលដោយប្រើឱសថជំនួស( កម្មវិធីមេតាដូន) ។

## ៣. ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តពង្រឹងយន្តការអនុវត្តគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

-រៀបចំប្រជុំរួមក្នុងនាយកដ្ឋានដើម្បីពិនិត្យលើចំនុចខ្លាំង-ចំនុចខ្សោយ នៃការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងពេលកន្លងមក និងរកវិធានការណ៍បង្រួមចំនុចខ្សោយ និងពង្រីកចំនុចខ្លាំង ។

-ទំនាក់ទំនងជាមួយការិយាល័យ UNODC ដើម្បីស្វែងរកលទ្ធភាពក្នុងការជួយពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋាន និងមន្ត្រីអនុវត្តន៏ច្បាប់នានា ដែលមានភារកិច្ចពាក់ពន្ធ័និងការត្រួតពិនិត្យសារធាតុគីមីផ្សំ ។

-រៀបចំឡើងវិញនូវផែនការ នៃការចលនាអោយមានការចូលរួមពីវិស័យឯកជន ពិសេសម្ចាស់រោងចក្រ សិប្បកម្ម អាជីវកម្ម ដែលប្រើប្រាស់សារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន ដើម្បីពង្រីកការគ្រប់គ្រង និងទប់ស្កាត់ការបង្វែរសារធាតុគីមីទៅផលិតគ្រឿងញៀនខុសច្បាប់ ។

## ៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ :

-រៀបចំគំរោងសំណើមួយចំនួនដែលពាក់ពន្ធ័ជាមួយនាយកដ្ឋានដើម្បីបញ្ចូលក្នុងកម្មវិធីពិភាក្សាជាមួយភាគីចិន ក្នុងកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដែលគ្រោងធ្វើឡើងនៅ ថ្ងៃទី១៧-២៣ ខែឧសភា ឆ្នាំ២០១០នៅកម្ពុជា។

-សំរបសំរួលជាមួយអូស្ត្រាលី ដើម្បីផ្តល់ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តន៏កម្ពុជា ពីជំនាញព័តិមានចារកម្ម។

-ត្រៀមចូលរួមអនុវត្តគំរោងអនុតំបន់របស់ UNODC ស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន(PATROL) ។

-ត្រៀមអនុវត្តគំរោងទ្វេភាគី កម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

-ត្រៀមចូលរួមក្នុងកិច្ចប្រជុំសំរបសំរួល **ASOD** ដើម្បីពិនិត្យផែនការសកម្មភាពអាស៊ាន នាថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១០ នៅប្រទេសឥណ្ឌូនេស៊ី ។

## ៥. នីតិកម្ម

-បន្តសំរបសំរួល និង សហការជាមួយក្រសួងយុត្តិធម៌ ដើម្បីធ្វើឱ្យបានសំរេចនូវសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅដើមខែឧសភាឆ្នាំ២០១០ តាមអនុសាសន៏ណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។

-បន្តជំរុញការរៀបចំអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសំរាប់បំពេញមុខងារតាមជំនាញ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរៀបចំបន្ថែមនូវគណៈកម្មាធិការស្វែងរកមូលនិធិសំរាប់ទ្រទ្រង់ដំណើរការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលគណៈកម្មាធិការនេះ ដឹកនាំដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

ដើម្បីអនុវត្តបានសំរេចទិសដៅខាងលើ អគ្គលេខាធិការដ្ឋាន អជបគញ នឹងខិតខំជំរុញការអនុវត្តន៏គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងយកចិត្តទុកដាក់លើការងារសំខាន់ៗមួយចំនួនទៀត ជាអាទិ៍ :

-រៀបចំផលិតសៀវភៅរបាយការណ៏ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៩ និង ទិសដៅការងារឆ្នាំ២០១០ ដោយចងក្រងខ្លឹមសារសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៩ និង ទិសដៅការងារ ឆ្នាំ២០១០ ភ្ជាប់ជាមួយ ។

-សម្របសម្រួលការវាយតម្លៃការអនុវត្តន៏គំរោងH83 ស្តីពីការអភិវឌ្ឍន៏សេវាប្រឹក្សាព្យាបាលនិងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៏ជាមូលដ្ឋានរបស់**UNODC**ជំហានទី២ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ។

-ការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលអនុវត្តគោលការណ៏ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

-ការរៀបចំផែនការជាតិ៥ឆ្នាំបន្ត (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅអំពីទិសដៅចំពោះមុខខាងលើ អគ្គលេខាធិការដ្ឋាន អជបគញ នឹងបន្តអនុវត្តតាមអនុសាសន៏ទាំង១២ចំណុច របស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

**-ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ**

**-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ**

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ